ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...............សហវ.........

# ប្រកាស
# ស្តីពី
# ការកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១.-**

ត្រូវបានកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម នៅក្រសួង ស្ថាប័ន រាជធានី ខេត្ត សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដូចមានក្នុងតារាងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ប្រការ២.-**

ត្រូវបានកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម នៅរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

**ប្រការ៣.-**

ហាមបំបែកគម្រោងជាគម្រោងតូចៗ ក្នុងគោលបំណងបំពានវិធីសាស្ត្រលទ្ធកម្ម ដូចខ្លឹមសារដែលមានចែងក្នុងមាត្រា៣៣ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានសហគ្រាសសាធារណៈ ប្រធានគ្រឹះស្ថានសាធារណៈរដ្ឋបាល និងប្រធានអង្គភាពចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ២០១៤

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

__ចម្លងជូន__

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ដូចក្នុងប្រការ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃប្រកាស

លេខ១០៩៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ ២០១៤

## តារាងកម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម
## នៅក្រសួង ស្ថាប័ន រាជធានី ខេត្ត សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល

| វិធីសាស្ត្រ | កម្រិតទឹកប្រាក់តាមប្រភេទលទ្ធកម្ម | | |
|---|---|---|---|
| | ទំនិញ | សំណង់ | សេវាកម្ម |
| ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ (ដ.ប.អ) | ចាប់ពី ៥.០០០លានរៀល ឡើង | ចាប់ពី ៦.០០០លានរៀល ឡើង | ចាប់ពី ៤.០០០លានរៀល ឡើង |
| ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក(ដ.ប.ស) | ចាប់ពី ១០០លានរៀល ដល់ក្រោម ៥.០០០លានរៀល | ចាប់ពី ១០០លានរៀល ដល់ក្រោម ៦.០០០លានរៀល | ចាប់ពី ១០០លានរៀល ដល់ក្រោម ៤.០០០លានរៀល |
| ការដេញថ្លៃមានកម្រិត(ដ.ក) | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ |
| ការពិគ្រោះថ្លៃ(ព.ថ) | ចាប់ពី ២០លានរៀល ដល់ក្រោម ១០០លានរៀល | ចាប់ពី ២០លានរៀល ដល់ក្រោម ១០០លានរៀល | ចាប់ពី ២០លានរៀល ដល់ក្រោម ១០០លានរៀល |
| ការស្ទង់តម្លៃ(ស.ត) | ក្រោម ២០លានរៀល | ក្រោម ២០លានរៀល | ក្រោម ២០លានរៀល |
| លទ្ធកម្មដោយឡែក(ល.ឡ) | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ |

ឧបសម្ព័ន្ធទី២នៃប្រកាស
លេខ១៨៦៦សហវ.ប្រក ចុះថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ ២០១៤

# តារាងកម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម
# នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

| វិធីសាស្ត្រ | កម្រិតទឹកប្រាក់តាមប្រភេទលទ្ធកម្ម | | |
|---|---|---|---|
| | ទំនិញ | សំណង់ | សេវាកម្ម |
| ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ (ដ.ប.អ) | ចាប់ពី ២.០០០លានរៀល ឡើង | ចាប់ពី ២.៥០០លានរៀល ឡើង | ចាប់ពី ១.៥០០លានរៀល ឡើង |
| ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក(ដ.ប.ស) | ចាប់ពី ១០០លានរៀល ដល់ក្រោម ២.០០០លានរៀល | ចាប់ពី ១០០លានរៀល ដល់ក្រោម ២.៥០០លានរៀល | ចាប់ពី ១០០លានរៀល ដល់ក្រោម ១.៥០០លានរៀល |
| ការដេញថ្លៃមានកម្រិត(ដ.ក) | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ |
| ការពិគ្រោះថ្លៃ(ព.ថ) | ចាប់ពី ១០លានរៀល ដល់ក្រោម ១០០លានរៀល | ចាប់ពី ២០លានរៀល ដល់ក្រោម ១០០លានរៀល | ចាប់ពី ១០លានរៀល ដល់ក្រោម ១០០លានរៀល |
| ការស្ទង់តម្លៃ(ស.ត) | ក្រោម ១០លានរៀល | ក្រោម ២០លានរៀល | ក្រោម ១០លានរៀល |
| លទ្ធកម្មដោយឡែក(ល.ឡ) | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ |